00681272

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire

លេខ/No៖ -30-

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អបជ (០៨)

ចំពោះមុខ៖ ចៅក្រម ប្រាក់ គីមសាន ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម នីយ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី៣ ខែឧសភា ឆ្នាំ ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 05 / 2011
ម៉ោង (Time/Heure): 14:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ: (កោសលុប)**

## សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំឲ្យធ្វើចំណាត់ឯកសារ អបជ ០៨ ទាំងអស់ឡើងវិញថាជាឯកសារសាធារណៈ

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Siegfried BLUNK

**ជនជាប់ចោទ**

លោក អៀង សារី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

[redacted]

លោក Dale LYSAK

**សហមេធាវីការពារក្តីជនជាប់ចោទ**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់លោក អៀង សារី សុំឱ្យធ្វើចំណាត់ថ្នាក់ឯកសារ អបជ ០៨ ទាំងអស់ឡើងវិញថាជាឯកសារសាធារណៈ" ដែលដាក់ដោយសហមេធាវីការពារក្តីរបស់លោក អៀង សារី នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ("សំណើ")[១]។

១. តាមរយៈសំណើរបស់ខ្លួន សហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ពីប្រភេទឯកសារ "សម្ងាត់បំផុត" មកជាប្រភេទឯកសារ "សាធារណៈ" ចំពោះរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿង អបជ០៨ ដែលទាក់ទងទៅនឹងការស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចំពោះការចោទប្រកាន់ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដោយនិយោជិកម្នាក់របស់ [redacted] ("ភាគីដែលត្រូវចោទ") ក្រោយពីមានសំណើរបស់សហមេធាវីការពារក្តី[២]។ សហមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា មិនមានហេតុផលណាមួយដែលត្រូវធ្វើចំណាត់ថ្នាក់ឯកសារទាំងអស់នេះថាជាឯកសារសម្ងាត់បំផុតនោះទេ ហើយថារាល់ភាគីទាំងអស់ សាធារណជន និងម្ចាស់ជំនួយរបស់ អ.វ.ត.ក មានសិទ្ធិដឹងអំពីបញ្ហានានាដែលបានលើកឡើងនៅក្នុងសំណុំរឿងមួយនេះ[៣]។

២. នៅថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំការអនុញ្ញាត ដើម្បីដាក់ចម្លើយតបទៅកាន់សំណើរបស់សហមេធាវីការពារក្តី[៤] ដែលចម្លើយតបរបស់សហព្រះរាជអាជ្ញានេះ ត្រូវបានអង្គបុរេជំនុំជម្រះបដិសេធចោល ដោយផ្អែកលើមូលដ្ឋានថា សហព្រះរាជអាជ្ញាមិនមានសិទ្ធិចូល

---

[១] សំណើរបស់ លោក អៀង សារី សុំឱ្យធ្វើចំណាត់ថ្នាក់ឯកសារ អបជ ០៨ ទាំងអស់ឡើងវិញថាជាឯកសារសាធារណៈ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ ២៤ ("សំណើសហមេធាវីការពារក្តី")។

[២] សំណើរបស់ លោក អៀង សារី សុំអោយស៊ើបអង្កេតក្រោមវិធានផ្ទៃក្នុង ៣៥ ចំពោះទង្វើនានារបស់ [redacted]

[៣] សំណើសហមេធាវីការពារក្តី កថាខណ្ឌ ១។

[៤] សំណើរបស់ [redacted] សុំការពន្យាពេលដាក់ចម្លើយតបរបស់ខ្លួន ទៅនឹងសំណើរបស់លោក អៀង សារី សុំធ្វើចំណាត់ការឡើងវិញលើឯកសារ អ.ប.ជ០៨ ទាំងអស់ជាសាធារណៈ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ ២៥។

00681274



រួមនៅក្នុងសំណើរបស់សហមេធាវីការពារក្តីនេះឡើយ ពីព្រោះអ្នកដែលត្រូវឆ្លើយតបមានតែមួយគត់ គឺ[redacted][5]។

៣. តាមរយៈចម្លើយតបដែលបានដាក់នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ភាគីដែលឆ្លើយតប ធ្វើការបដិសេធចំពោះការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញឱ្យទៅជាប្រភេទឯកសារ "សាធារណៈ" ដោយផ្អែកលើមូលដ្ឋានថា (១) អង្គបុរេជំនុំជម្រះបានរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរនេះបានយ៉ាងត្រឹមត្រូវនៅក្នុងសំណុំរឿងនេះ (២) ការលាតត្រដាងទៅសាធារណជនអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់គាត់ និង (៣) សហមេធាវីការពារក្តីព្យាយាមដោះស្រាយបញ្ហានេះ នៅលើវេទិកាសាធារណៈ ជាជាងតាមរយៈមធ្យោបាយសមស្របនានា[6]។

៤. សហមេធាវីការពារក្តីបានដាក់ការឆ្លើយតបរបស់ខ្លួនកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ ("ការឆ្លើយតប")[7]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ") វិសោធនកម្មលើកទី៦[8] ដែលជាមូលដ្ឋាននៃសំណើនេះ ហើយដែលនឹងត្រូវពិភាក្សាបន្ថែមខាងក្រោមនេះចែងថា ភាគីនានាអាចត្រូវបានផ្តល់ឱ្យនូវឱកាសដើម្បីធ្វើការឆ្លើយតប មុនពេលមានការសម្រេចធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដោយអង្គជំនុំជម្រះ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ប្រសិនបើភាគីណាមួយស្នើសុំឱ្យមានការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ នៅក្នុងករណីកិច្ចស៊ើបសួរ ក្រោមការចោទប្រកាន់ថាមានការជ្រៀតជ្រែកចូលក្នុងរដ្ឋបាលរបស់តុលាការ ដែលជានីតិវិធីពិសេសនោះ (*sui generis*) ភាគីមានសិទ្ធិបង្ហាញពីមតិយោបល់របស់ខ្លួនបានតែម្តងតែប៉ុណ្ណោះ

---

[5] សេចក្តីសម្រេចលើសំណើរបស់[redacted] សុំពន្យាពេលដាក់ចម្លើយតប ចំពោះសំណើរបស់ អៀង សារី សុំឱ្យដាក់ចំណាត់ថ្នាក់ឯកសារ អ.ស.ប ទាំងអស់ជាឯកសារសាធារណៈ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ ២៦។

[6] ចម្លើយតបរបស់ [redacted] ទៅនឹងសំណើរបស់ លោក អៀង សារី សុំឱ្យធ្វើចំណាត់ឯកសារ អបជ០៨ ទាំងអស់ឡើងវិញវាជាឯកសារសាធារណៈ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ ២៧ កថាខណ្ឌ ១។

[7] ការឆ្លើយតបទៅនឹងចម្លើយតបរបស់[redacted] ទៅនឹងសំណើរបស់លោក អៀង សារី សុំឱ្យដាក់ចំណាត់ថ្នាក់ឯកសារ អ.ស.ប (០៨) ទាំងអស់ឡើងវិញថាជាឯកសារសាធារណៈ ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ ២៨ កថាខណ្ឌ ១។

[8] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី៦ ដែលបានកែប្រែនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១១។

និងមិនមានសិទ្ធិធ្វើការឆ្លើយតបទៅកាន់សារណាតបរបស់ភាគីម្ខាងទៀតឡើយ។ នៅគ្រប់កាលៈ-ទេសៈទាំងអស់ បុគ្គលដែលរងការប៉ះពាល់ដោយនីតិវិធី ដែលត្រូវបានស្នើឱ្យបើកចំហដល់សាធារណជននោះ (ក្នុងករណីនេះ បុគ្គលនោះគឺជាភាគីដែលត្រូវបានឆ្លើយតប) នឹងត្រូវបានស្តាប់មតិយោបល់ចុងក្រោយគេបង្អស់។ ហេតុដូច្នេះ ការឆ្លើយតបនេះនឹងមិនត្រូវបានពិចារណាឡើយ។

៥. ក្រោយពីបានដាក់រួចមក ឯកសារនានានៅក្នុងសំណុំរឿង អបជ០៨ ត្រូវបានធ្វើចំណាត់ថ្នាក់ដោយអង្គបុរេជំនុំជម្រះថាជាឯកសារ "សម្ងាត់បំផុត"។ ដូច្នេះឯកសារទាំងនោះត្រូវបាន និងនៅតែ "បើកចំហរជូនចំពោះតែចៅក្រម បុគ្គលផ្សេងទៀតដែលរួមមានបុគ្គលិកតុលាការដែលត្រូវការពិនិត្យមើលឯកសារដើម្បីបំពេញភារកិច្ចរបស់ខ្លួន ប៉ុន្តែសិទ្ធិមើលឯកសារត្រូវទទួលបានសេចក្តីសម្រេចពីតុលាការជាមុន" ស្របតាមសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មាន ទាក់ទងនឹងសំណុំរឿង ("សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ")[៥]។

៦. សំណើរបស់សហមេធាវីការពារក្តី ធ្វើឡើងដោយផ្អែកលើមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ដែលចែងថា ឯកសារនានានៅក្នុងសំណុំរឿងអាចត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញដោយអង្គបុរេជំនុំជម្រះ ក្នុងចំណោមអង្គជំនុំជម្រះផ្សេងៗទៀត បន្ទាប់ពីបានស្តាប់ពីភាគីនានារួចហើយ។ បទប្បញ្ញត្តិនេះមានខ្លឹមសារដូចខាងក្រោមនេះ៖

> "៣.១៤ តម្រូវតាមផលប្រយោជន៍យុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលគ្រប់គ្រងសំណុំរឿង អាចធ្វើចំណាត់ប្រភេទឯកសារជាថ្មីក្នុងសំណុំរឿង។ ភាគីជាប់ពាក់ព័ន្ធនឹងត្រូវផ្តល់ឱកាសឱ្យបានដឹង និងធ្វើការឆ្លើយតប មុនមានការធ្វើសេចក្តីសម្រេចបែបនេះ ឬ អំឡុងពេលធ្វើចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន ដែលជាការចាំបាច់ក្នុងការការពារព័ត៌មាន ដែលអាចជាព័ត៌មានសម្ងាត់ ឬ សម្ងាត់បំផុត។ នៅក្នុងករណីនេះ ភាគីពាក់ព័ន្ធនឹងសំណុំរឿង ត្រូវបានជូនដំណឹងអំពីការធ្វើចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន និង អំពីសេចក្តីសម្រេចធ្វើចំណាត់ប្រភេទជាថ្មី។"

៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បទប្បញ្ញត្តិនានានៅក្នុងសេចក្តីណែនាំអនុវត្ត ដែលពាក់ព័ន្ធទៅនឹងភាពសម្ងាត់របស់ឯកសារ ដោយរួមទាំងមាត្រា ៣.១៤ ដែលសហមេធាវីការពារក្តីយកធ្វើជាមូលដ្ឋាននោះ ទាក់ទិនទៅនឹងកម្រិតនៃភាពសម្ងាត់របស់ឯកសារនានាដែលមាននៅក្នុងសំណុំរឿង

---

[៥] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទ និង ការគ្រប់គ្រងព័ត៌មានដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២០០៩ អនុម័តនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៩ មាត្រា ២(ឃ)(ii)។

បន្ទាប់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាត្រូវបានដាក់[១០]។ បទប្បញ្ញត្តិទាំងនេះ មិនដោះស្រាយជាក់លាក់ចំពោះករណីទាំងឡាយនៃកិច្ចស៊ើបសួរលើការចោទប្រកាន់ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដែលករណីនេះត្រូវចាត់ថាជានីតិវិធីពិសេសនោះទេ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះពិចារណាឃើញថា បើទោះជាមិនមានបទប្បញ្ញត្តិជាក់លាក់នានា សម្រាប់ភាពសម្ងាត់នៃករណីជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់តុលាការនោះ បទប្បញ្ញត្តិទាំងនេះអាចយកមកប្រើធ្វើជាសេចក្តីណែនាំមួយ ដើម្បីឱ្យអង្គជំនុំជម្រះសម្រេចលើបញ្ហាចំពោះមុខមួយនេះបាន ពីព្រោះបទប្បញ្ញត្តិទាំងនេះផ្តល់ឱ្យនូវការបញ្ជាក់ដ៏មានប្រយោជន៍ស្តីពីអំណាចរបស់អង្គជំនុំជម្រះក្នុងការសម្រេចលើកម្រិតនៃភាពសម្ងាត់របស់ឯកសារ និងលទ្ធភាពនៃសំណើសុំឱ្យធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។

៨. ជាពិសេស សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ និងសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារចែងថា ភាគីណាមួយដែលដាក់ឯកសារនៅក្នុងសំណុំរឿងព្រហ្មទណ្ឌអាចស្នើសុំការធ្វើចំណាត់ប្រភេទឯកសារបាន ប៉ុន្តែបញ្ហានេះនឹងស្ថិតនៅលើតុលាការដែលបានទទួលសំណុំរឿងនោះ ក្នុងការសម្រេចទៅលើការធ្វើចំណាត់ប្រភេទឯកសារសមស្រប[១១] ដោយតុលាការពិចារណាទៅលើ "តុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការដែលមិនបើកចំហរដល់សាធារណជន តម្រូវឱ្យធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរ្តិ៍ដំណែល"[១២]។ បើទោះជាសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ ផ្តល់ឱ្យជាការណែនាំអំពីប្រភេទឯកសារសំណុំរឿងដែលត្រូវចាត់ជាឯកសារ "សាធារណៈ", "សម្ងាត់", ឬ "សម្ងាត់បំផុត" ដោយបង្កើតឱ្យមានជាគោលការណ៍ដែលអាចអនុវត្តបាន នៅពេលដែលគ្មានសេចក្តីសម្រេចរបស់តុលាការនោះ សេចក្តីណែនាំអនុវត្តនេះក៏បញ្ជាក់ច្បាស់ផងដែរថា អង្គជំនុំជម្រះដែលទទួលសំណុំរឿង គឺជាអ្នកសម្រេចអំពីការធ្វើចំណាត់ប្រភេទឯកសារនានា[១៣]។ គួរកត់សម្គាល់ថា មិនមានការបញ្ជាក់ណាមួយដែលបង្ហាញថាតើឯកសារនានា ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតលើការចោទប្រកាន់

[១០] សូមមើល ជាពិសេស មាត្រា ១.១, មាត្រា ៣.១២ និង មាត្រា ៣.១៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

[១១] មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

[១២] មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ។ *សូមមើលផងដែរ* វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[១៣] សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ប្រភេទឯកសារ មាត្រា ៤ ដល់ មាត្រា ៦។



អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការនោះ នឹងត្រូវធ្វើចំណាត់ប្រភេទបាន ដោយយ៉ាងដូចម្ដេចនោះទេ នៅពេលដែលគ្មានសេចក្ដីសម្រេចរបស់តុលាការលើបញ្ហានេះ ដោយសារតែសេចក្ដីណែនាំអនុវត្តស្ដីពីការធ្វើចំណាត់ប្រភេទឯកសារនេះ ចែងពាក់ព័ន្ធតែទៅនឹងការសម្ងាត់របស់ឯកសារនៅក្នុងសំណុំរឿងព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ដោយកត់សម្គាល់ថា វិធានជាធរមាននៅ អ.វ.ត.ក ផ្ដល់ឆន្ទានុសិទ្ធិដល់ស្ថាប័នតុលាការដែលទទួលសំណុំរឿងព្រហ្មទណ្ឌ ក្នុងការសម្រេចលើកម្រិតនៃភាពសម្ងាត់របស់ឯកសារ ដោយពិចារណាលើតុល្យភាពរវាងផលប្រយោជន៍នានានោះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា គោលការណ៍ដូចគ្នានេះ អាចអនុវត្តបាននៅពេលដែលយើងដោះស្រាយជាមួយប្រភេទសំណុំរឿងផ្សេងៗទៀត ដែលមិនមានចែងច្បាស់លាស់នៅក្នុងសេចក្ដីណែនាំអនុវត្តទាំងនេះ។

៩. នៅពេលដែលមិនមានវិធានណាមួយនៅក្នុងច្បាប់កម្ពុជា ដែលអាចយកមកដោះស្រាយបញ្ហានេះបាន តាមការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះអាចស្វែងរកការណែនាំនៅក្នុងវិធានស្ដីពីនីតិវិធីដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ដូចបានបង្គាប់ដោយមាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទិននឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ ក្នុងករណីនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា តុលាការអន្តរជាតិផ្សេងៗទៀតដែលមានដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ហៅកាត់ជាភាសាអង់គ្លេសថា “ICTY”) និង តុលាការព្រហ្មទណ្ឌអន្តរជាតិ (ហៅកាត់ជាភាសាអង់គ្លេសថា “ICC”) បានអនុម័តនូវវិធានជាក់លាក់មួយចំនួនដែលចែងថា ឯកសារនានាពាក់ព័ន្ធនឹងកិច្ចស៊ើបសួរទៅលើការចោទប្រកាន់ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ឬកំហុសរបស់មន្ត្រីតុលាការ ឬមេធាវី ត្រូវជាព័ត៌មានសម្ងាត់[១៤]។ នៅ ICTY លើកលែងតែមានការសម្រេចពីអង្គជំនុំជម្រះថាមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីប្ដឹងប្រឆាំងលើបុគ្គលណាមួយពីបទប្រមាថតុលាការ នោះទើបសំណុំ

[១៤] ICTY៖ សេចក្ដីណែនាំអនុវត្តស្ដីពីនីតិវិធីសម្រាប់កិច្ចស៊ើបសួរ និង ការកាត់សេចក្ដីលើបទប្រមាថតុលាការ នៅចំពោះមុខតុលាការអន្តរជាតិ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤ ឯកសារ IT/227 (“សេចក្ដីណែនាំអនុវត្តរបស់ ICTY”) មាត្រា ៥, មាត្រា ៨, មាត្រា ៩ និង មាត្រា ១១។ ICC៖ ក្រមសីលធម៌វិជ្ជាជីវៈរបស់មេធាវី ឯកសារ ICC-ASP/4/Res.1 ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៥ មាត្រា ៣៤(៥) (ដែលចែងអំពីភាពសម្ងាត់នៃបណ្ដឹងពីកំហុសមេធាវី) មាត្រា ៣៨(៣) (ដែលចែងពីភាពសម្ងាត់នៃរាល់ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការដាក់ពិន័យ)។ សូមមើលឯកសាររបស់ ICC៖ វិធានស្ដីពីនីតិវិធី និងការដាក់ភស្តុតាង មាត្រា ២៦(១) (ដែលចែងអំពីភាពសម្ងាត់នៃបណ្ដឹងពីកំហុសរបស់មន្ត្រីតុលាការ)។

00681278



រឿងនេះដាក់ជាសាធារណៈបាន[១៥]។ វិធានទាំងនេះគឺជាការបញ្ជាក់យ៉ាងមុតមាំថា នៅក្នុងសំណុំរឿងនៃកិច្ចស៊ើបសួរលើការចោទប្រកាន់ថា មានការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ ភាពចាំបាច់ក្នុងការរក្សាកេរ្តិ៍ឈ្មោះរបស់បុគ្គល អាចមានទម្ងន់ធ្ងន់ជាងភាពចាំបាច់ក្នុងការដាក់កិច្ចដំណើរការនីតិវិធីជាសាធារណៈ។ ដូចមានមូលហេតុរៀបរាប់ខាងក្រោមនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា យុទ្ធសាស្ត្រស្រដៀងគ្នានេះអាចយកមកអនុវត្តបាននៅក្នុងសំណុំរឿងនាពេលនេះ។

១០. អង្គជំនុំជម្រះសង្កត់ធ្ងន់ថា សំណុំរឿងនាពេលនេះពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរ ដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៣៥(២)(ខ) ចំពោះការចោទប្រកាន់ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ដែលធ្វើឡើងដោយសហមេធាវីការពារក្តីប្រឆាំងលើនិយោជិកម្នាក់របស់[redacted]។ បន្ទាប់ពីបានបើកកិច្ចស៊ើបសួររួចហើយ និងដោយផ្អែកលើសក្ខីកម្ម[redacted] នៅក្នុងអំឡុងពេលសវនាការអសាធារណៈរួចមក អង្គបុរេជំនុំជម្រះបានរកឃើញថា "នៅក្នុងរឿងក្តីនេះ មិនមានអង្គហេតុណាមួយបង្ហាញថា [redacted] បានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់ អ.វ.ត.ក ដែលវាផ្ទុយនឹងវិធានផ្ទៃក្នុង ៣៥(១) ដូចបានអះអាងឡើងក្នុងសំណើនោះឡើយ។ ហេតុដូច្នេះ មិនមានមូលដ្ឋានណាមួយគ្រប់គ្រាន់ក្នុងការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង[redacted] អនុលោមតាមវិធានផ្ទៃក្នុង ៣៥(២)(ខ) ឡើយ"[១៦]។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង អបជ០៨ ចំពោះការចោទប្រកាន់នានា ដែលត្រូវបានរកឃើញថាមិនមានមូលដ្ឋានគ្រប់គ្រាន់។ នៅក្នុងអំឡុងពេលសវនាការ សហមេធាវីការពារក្តីខ្លួនឯងផ្ទាល់បានជម្រាបដល់សហចៅក្រមរបាយការណ៍ថា ខ្លួនពេញចិត្តទៅនឹងចម្លើយដែលផ្តល់ឲ្យហើយ "យើងពេញចិត្តនៅក្នុងដំណាក់កាលនេះ"[១៧]។

---

[១៥] សេចក្តីណែនាំអនុវត្តរបស់ ICTY មាត្រា ១៥។

[១៦] សាលដីកាលើកទី៤ លើសំណើរបស់ អៀង សារី សុំឲ្យមានការស៊ើបសួរក្រោមវិធានផ្ទៃក្នុង ៣៥ ចំពោះសកម្មភាពរបស់[redacted]

[១៧] ប្រតិចារិកនៃសវនាការ ដែលធ្វើឡើងនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ទំព័រ ១៤។




PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

១១. អង្គបុរេជំនុំជម្រះសង្កត់ធ្ងន់ថា មិនមានកិច្ចដំណើរការនីតិវិធីតុលាការត្រូវបានចាប់ផ្តើមនៅក្នុងសំណុំរឿងនេះឡើយ។ ហេតុដូច្នេះ ចំណាប់អារម្មណ៍របស់សាធារណជនចំពោះឯកសារនានានៅក្នុងសំណុំរឿងនេះ មានកម្រិតទាប និងមិនមានទម្ងន់ធ្ងន់ជាងភាពចាំបាច់ ដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់បុគ្គលដែលពាក់ព័ន្ធឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅក្នុងឯកសាររបស់ខ្លួនដែលបានដាក់ និងជាពិសេសនៅក្នុងសំណើ និងការឆ្លើយតបរបស់ខ្លួននាពេលនេះ សហាមេធាវីការពារក្តីបន្តចោទប្រកាន់ថាមានកំហុសវិជ្ជាជីវៈរបស់មន្ត្រីរបស់តុលាការមួយចំនួន ដែលតាមការលើកឡើងរបស់សហាមេធាវីការពារក្តីកើតចេញពីកិច្ចស៊ើបសួរ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការចោទប្រកាន់ទាំងនេះងាកចេញឆ្ងាយពីលទ្ធផលនៃកិច្ចស៊ើបសួរ ហើយការលាតត្រដាងនូវព័ត៌មានបែបនេះអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់បុគ្គលទីបី ដែលមិនមែនជាភាគីនៅក្នុងកិច្ចនីតិវិធីនាពេលនេះ។

១២. នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចថា ឯកសារនានានៅក្នុងសំណុំរឿង អបជ ០៨ នឹងនៅតែជាឯកសារ “សម្ងាត់បំផុត” ដដែល។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

ច្រានចោលសំណើរបស់សហាមេធាវីការពារក្តី។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ ២០១១

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

Rowan DOWNING **នេយ ថុល** Katinka LAHUIS **ហួត វុទ្ធី** **ប្រាក់ គីមសាន**